## វគ្គ I



# ថ្ងៃខួបកំណើតដ៏អាក្រក់បំផុត

មិនមែនត្រឹមតែលើកដំបូងនោះទេ ដែលជម្លោះប្រកែកមួយបានកើតឡើង នៅពេលទទួលទានអាហារពេលព្រឹកឯមហាវិថីប្រាយវេដ ជ្រាយ ផ្ទះលេខបួន។ លោកវើរណុន ឌើស្លីត្រូវបានដាស់ឲ្យភ្ញាក់ពីដំណេកតាំងពីព្រលឹមម្ល៉េះដោយសារសម្លេងទីទុយយំដ៏ថ្លង់ពីបន្ទប់ក្មួយប្រុសរបស់គាត់ ឈ្មោះហេរី។

- បីដងហើយក្នុងមួយសប្តាហ៍នេះ!- គាត់បានគ្រហឹមកាត់តុ។ - ប្រសិនជាឯងមិនអាចគ្រប់គ្រងទីទុយនោះបានទេ វានឹងត្រូវតែទៅហើយ!

ហេរីបានព្យាយាមពន្យល់ម្តងហើយម្តងទៀត។

- វាធុញណាស់- វាបាននិយាយ។ - វាធ្លាប់តែចេញហើរជុំវិញនៅខាងក្រៅ។ ប្រសិនបើខ្ញុំអាចឲ្យវាចេញហើរនៅពេលយប់បាននោះ...

- តើអញមើលទៅដូចមនុស្សភ្លើរឺ?- លោកមាវើរណុនបានគ្រហឹម ដោយមានកំទេចពងទាចៀនសំយុងចុះមកពីពុកមាត់ដ៏ស្រមូររបស់គាត់។ - អញដឹងថានឹងមានអ្វីកើតឡើងប្រសិនបើឲ្យអាទីទុយនោះចេញទៅក្រៅ។

គាត់បានផ្លាស់ប្តូរនូវទឹកមុខខ្មោងងឹតជាមួយនឹងប្រពន្ធរបស់គាត់ ពីទូនៀ។

ហេរីព្យាយាមឈ្លោះតបវិញ ប៉ុន្តែពាក្យសម្តីរបស់វាទាំងអម្បាលម៉ានត្រូវរលាយទៅវិញដោយសម្លេងភើដ៏ខ្លាំងចេញពីកូនរបស់គ្រួសារឌើស្លី ដាត់លី។

- ខ្ញុំត្រូវការខ្លាញ់ជុំប្រឡាក់ទៀត។

- មានទៀតនៅក្នុងខ្ទះចៀន កូនសម្លាញ់- អ្នកមីងពីទូនៀបានស្រដី ដោយបែរក្រសែភ្នែកដ៏ស្រអាប់ដាក់កូនប្រុសកន្ធាត់របស់គាត់។ - យើងត្រូវតែចិញ្ចឹមកូនខណៈពេលដែលយើងនៅមានឱកាស....ម៉ាក់មិនចូលចិត្តម្ហូបអាហារនៅសាលានោះសោះ...

-គ្មានបានការទេ ពីទូនៀ បងមិនដែលឃ្លានម្តងណាឡើយនៅពេលដែលបងរៀននៅ ស្មែលទីង្គ នោះ- លោកមាវើរណុននិយាយយ៉ាងពេញចិត្តពេញថ្លើម។ - ដាត់លីទទួលបានល្មមគ្រប់គ្រាន់ហើយ មែនទេ កូនប្រុស?

ដាត់លី ដែលមានមាឌធំក្រអាញ គូទរបស់វាទ្រោមទៅលើជ្រុងទាំងសងខាងកៅអី បានសើចស្ងេញ ហើយបែរទៅរកហេរី។

- យកខ្នុះចៀនបន្តិចមើល៎។

- ឯងភ្លេចពាក្យវេទមន្តហើយ - ហេរីបាននិយាយយ៉ាងមួម៉ៅជាខ្លាំង។

ការជះឥទ្ធិពលនៃប្រយោគដ៏សាមញ្ញនេះទៅលើមនុស្សក្នុងគ្រួសារឌើស្លីពិតជាមិនគួរឲ្យជឿទាល់តែសោះ៖ ដាត់លីដង្ហក់ដង្ហើម ហើយធ្លាក់ចុះពីកៅអីរបស់វាជាមួយនឹងសម្លេងទង្គិចដែលធ្វើឲ្យរញ្ជួយផ្ទះបាយទាំងមូល ឯអ្នកស្រីឌើស្លីបានបន្លឺសម្រែកដ៏តូចមួយ ហើយយកដៃខ្ទប់មាត់របស់គាត់ រីឯលោកឌើស្លីវិញបានក្រោកឈរឡើង ដោយសរសៃឈាមកំពុងតែលោតនៅក្នុងសៀតផ្ការបស់គាត់។

- ខ្ញុំចង់មានន័យថា «សូមមេត្តា»! - ហេរីបានស្រដីយ៉ាងរហ័ស។ - ខ្ញុំមិនមែនមានន័យថា...

- តើយើងបានប្រាប់ឯងយ៉ាងម៉េចខ្លះ- លោកមារបស់វាបានស្រែក ដោយខ្ចាតទឹកមាត់ទៅលើតុ - ពីរឿងនិយាយពាក្យ "វ" នៅក្នុងផ្ទះរបស់យើង?

- ប៉ុន្តែ ខ្ញុំ...

- ឯងថ្លើមធំហ៊ានគំរាមដាត់លីផងរី!- លោកមាវើរណុនបានគ្រហឹម ដោយដំគុននឹងកណ្តាប់ដៃរបស់គាត់។

- អញសូមព្រមានឯង! អញនឹងមិនអនុញ្ញាតឲ្យនិយាយពីភាពមិនធម្មតារបស់ឯងនៅក្រោមដំបូលផ្ទះនេះទេ!

ហេរីសម្លឹងមើលពីមុខពណ៌ផ្កាឈូករបស់លោកមាវើរណុនទៅអ្នកមីងរបស់វាដែលស្លេកស្លាំង ហើយកំពុងតែព្យាយាមលើកដាត់លីឲ្យក្រោកឈរឡើង។

- មិនអីទេ- ហេរីនិយាយ - មិនអីទេ...

លោកមាវើរណុនក៏អង្គុយចុះវិញ ដោយដកដង្ហើមដូចជារមាសដែលមានដង្ហើមផុតៗ ហើយសម្លឹងមើលហេរីយ៉ាងជាប់នឹងជ្រុងម្ខាងនៃភ្នែកដ៏តូច និងមុតស្រួចរបស់គាត់។

តាំងពីពេលដែលហេរីត្រលប់មកផ្ទះវិញនៅវិស្សមកាលរដូវក្តៅ លោកមាវើរណុនបានចាត់ទុកហេរីដូចជាគ្រាប់បែកមួយដែលអាចនឹងផ្ទុះគ្រប់ពេល ពីព្រោះហេរីមិនមែនជាក្មេងធម្មតាម្នាក់នោះទេ។ តាមពិតទៅ វាមិនមែនធម្មតាដូចសំបកក្រៅរបស់វាឡើយ។

ហេរី ផោតធ័រ គឺជាវេទគូម្នាក់...ជានិស្សិតវេទគូមកពីសាលាហុកវ៉ាតឆ្នាំទីមួយ។ ហើយប្រសិនបើក្រុមគ្រួសារឌើស្លីមិនពេញចិត្តនឹងឲ្យវាមកវិញនៅថ្ងៃឈប់សម្រាក ក៏គ្មានអ្វីប៉ះពាល់ដល់អារម្មណ៍របស់វាដែរ។

វានឹកសាលាហុកវ៉ាតខ្លាំងណាស់ ដូចជាការចុកពោះមិនចេះបាត់អញ្ចឹង។ វានឹកប្រាសាទ ដែលមានច្រកផ្លូវសម្ងាត់ ហើយនិងខ្មោច មេរៀនរបស់វា (ទោះបីប្រហែលជាមិនមែនស្នេបក៏ដោយ ដែលជាគ្រូឱសថ) សំបុត្រផ្ញើតាមទីទុយ ការទទួលទានអាហារក្នុងពិធីជប់លៀងនៅក្នុងមហាសាល ដេកក្នុងគ្រែមានបង្គោលបួននៅក្នុងប៉មសយនដ្ឋាន ការទៅសួរសុខទុក្ខឆ្មាំប្រមាញ់ ហាហ្គ្រីដនៅក្នុងផ្ទះរបស់គាត់នៅលើដីជាប់នឹងព្រៃហាមឃាត់ ហើយ ជាពិសេសបំផុតនោះ គឺកីឡាឃ្វីដឌីច្ច ដែលជាកីឡាដ៏ពេញនិយមបំផុតនៅក្នុងពិភពវេទមន្ត (បង្គោលខ្ពស់ៗប្រាំមួយ បាល់ហោះបួន ហើយនិងកីឡាករជប់បួននាក់នៅលើដងអំបោស)។

## ថ្ងៃខួបកំណើតដ៏អាក្រក់បំផុត

សៀវភៅវេទមន្ត ចង្កឹះវេទមន្តរបស់វា អាវរ៉ូប ថ្លាង និងដងអំបោសនីមប៊ូសពីរពាន់ចំនាត់ថ្នាក់កំពូលរបស់ហេរីទាំងអស់ត្រូវចាក់សោរទុកក្នុងបន្ទប់ក្រោមជណ្តើរដោយលោកមាវើរណុនពេលដែលហេរីមកដល់ផ្ទះភ្លាម។ មានអ្វី ដែលក្រុមគ្រួសារឌើស្លីត្រូវខ្វាយខ្វល់ប្រសិនបើហេរីបាត់បង់តំណែងរបស់វានៅក្នុងក្រុមឃ្វីដឌីចដោយសារតែវាមិនបានហាត់សមពេញមួយរដូវក្តៅនោះ? មានអ្វីត្រូវខ្វល់ប្រសិនបើហេរីត្រលប់ទៅសាលាវិញដោយមិនបានធ្វើកិច្ចការសាលាបន្តិចសោះនោះ? ក្រុមគ្រួសារឌើស្លីគឺជាអ្វីដែលពួកវេទគូហៅថាពួកលោកិយ (គ្មានសូម្បីតែឈាមវេទមន្តមួយតំណក់នៅក្នុងសរសៃឈាមរបស់ពួកគេ) តាមដែលពួកគេដឹង ការមានវេទគូនៅក្នុងគ្រួសារគឺជាបញ្ហាអាម៉ាស់មុខដ៏ខ្លាំង។ លោកមាវើរណុនថែមទាំងបានចាក់សោទីទុយរបស់ហេរី ឈ្មោះហ៊ីដវីក នៅក្នុងទ្រុងរបស់វាទៀតផង ដើម្បីកុំឲ្យវានាំសារទៅកាន់នរណាម្នាក់នៅក្នុងពិភពវេទមន្ត។

ហេរីមើលទៅមិនដូចជាសមាជិកនៅក្នុងគ្រួសារនេះទេ។ លោកមាវើរណុនមានមាឌធំ ហើយស្ទើរតែគ្មានក ដោយមានពុកមាត់ពណ៌ខ្មៅដ៏ធំសំបើម ឯអ្នកមីងពីទូនៀមានមុខដូចសេះ ហើយសុទ្ធតែឆ្អឹង រីឯដាត់លីវិញសក់ពណ៌ទង់ដែង ផ្កាឈូក និងធាត់ដូចជ្រូក។ ផ្ទុយស្រលះពីគ្នា ហេរីមាននរាងតូច ហើយស្គម ដោយមានភ្នែកពណ៌បៃតងដ៏មុតថ្លា និងសក់ខ្មៅគ្រិបដែលតែងតែរញ៉េរញ៉ៃ។ វាពាក់វ៉ែនតារាងមូល ហើយនៅលើថ្ងាសរបស់វាមានស្នាមសម្លាករាងដូចផ្លេកបន្ទោរដ៏ស្តើងមួយ។

ស្លាកស្នាមនេះហើយដែលធ្វើឲ្យហេរីមិនធម្មតាដែលខុសប្លែកពីគេឯង សូម្បីចំពោះវេទគូម្នាក់។ ស្នាមនេះជាសញ្ញាណតែមួយគត់នៃអតីតកាលដ៏អាថ៌កំបាំងរបស់ហេរី នៃមូលហេតុដែលវាត្រូវបានគេទុកចោលនៅលើផ្លូវដើរទៅកាន់ទ្វារមុខផ្ទះរបស់គ្រួសារឌើស្លីកាលពីដប់មួយឆ្នាំមុន។

នៅអាយុមួយឆ្នាំ ទោះបីជាយ៉ាងណាក៏ដោយ ហេរីបានទទួលនូវសិល្បបណ្តាសាពីវេទគូងងឹតដ៏ខ្លាំងអស្ចារ្យម្នាក់មិនចេះសាបរលាប គឺវ៉ុលដឺម៉រ ដែលឈ្មោះរបស់គេមេធ្មប់ និងវេទគូស្ទើរតែទាំងអស់នៅតែខ្លាចមិនហ៊ាននិយាយ។ ឪពុកម្តាយរបស់ហេរីស្លាប់ដោយសារការវាយប្រហាររបស់វ៉ុលដឺម៉រ ប៉ុន្តែហេរីបានគេចខ្លួនជាមួយនឹងស្នាមផ្លេកបន្ទោររបស់វា ហើយទោះបីជាយ៉ាងណាក៏ដោយ...គ្មាននរណាម្នាក់ដឹងថាហេតុអ្វីនោះទេ...បានជាថាមពលរបស់វ៉ុលដឺម៉រត្រូវបានបំផ្លាញខណៈពេលដែលគាត់បរាជ័យក្នុងការសម្លាប់ហេរី។

ដូច្នេះហេរីត្រូវបានយកមកចិញ្ចឹមដោយបងស្រីរបស់ម្តាយវាដែលបានចែកឋានទៅ ហើយនិងប្តីរបស់គាត់។ វាបានចំណាយពេលដប់ឆ្នាំរស់នៅជាមួយនឹងគ្រួសារឌើស្លី ដោយមិនដឹងថាហេតុអ្វីបានជាវាធ្វើឲ្យរឿងរ៉ាវចម្លែកៗកើតឡើងជាបន្តបន្ទាប់ដោយគ្មានចេតនា ជឿរឿងរបស់គ្រួសារឌើស្លីដែលថា វាមានស្នាមនេះដោយសារការក្រឡាប់ឡានដែលបានសម្លាប់ឪពុកម្តាយរបស់វា។

ហើយបន្ទាប់មក យ៉ាងជាក់លាក់កាលពីមួយឆ្នាំកន្លងទៅ សាលាហុកវ៉ាតបានសរសេរសំបុត្រមកហេរី ហើយរឿងរ៉ាវទាំងមូលបានធ្លាយចេញមក។ ហេរីបានទៅរៀននៅសាលាវេទមន្ត ដែលវា និងស្នាមសម្លាករបស់វាមានភាពល្បីល្បាញ...ប៉ុន្តែឥលូវឆ្នាំសិក្សាត្រូវបានបញ្ចប់ហើយ ហើយវាត្រូវត្រលប់មកគ្រួសារឌើស្លីវិញនៅរដូវក្តៅ ត្រលប់មកឲ្យគេចាត់ទុកជាសុនខដែលដើរត្លុកក្នុងរឿងអាក្រក់។

គ្រួសារឌើស្លីថែមទាំងមិនចាំថាថ្ងៃនេះជាថ្ងៃបុណ្យខួបកំណើតទីដប់ពីររបស់ហេរីផងនោះទេ។ ជាការពិតណាស់ ក្តីសង្ឃឹមរបស់វាមិនជាខ្ពស់ណាស់ណាទេ ពួកគេមិនដែលឲ្យវានូវអំណោយសមរម្យម្តងណាឡើយ គ្រាន់តែឲ្យនំទទេរ...ប៉ុន្តែព្រងើយកន្តើយនឹងវាទាំងស្រុង...

នៅខណៈនោះ លោកមាវើរណុនបានជម្រះបំពង់ករបស់គាត់ដូចជាមានការសំខាន់ ហើយនិយាយថា៖

- ឥលូវ ដូចដែលយើងដឹងស្រាប់ហើយ ថ្ងៃនេះជាថ្ងៃសំខាន់ណាស់។

ហេរីងើយមើល ដោយពិបាកនឹងហ៊ានជឿ។

- នេះជាថ្ងៃដ៏ល្អបំផុតដែលខ្ញុំធ្វើកិច្ចសន្យាដ៏ធំមួយពីការងាររបស់ខ្ញុំ- លោកមាវើរណុនបានស្រដី។

ហេរីត្រលប់ទៅរកនំប៉័ងអាំងរបស់វាវិញ។ ជាការពិតណាស់ វាបានគិតយ៉ាងល្វីងជូរចត់ លោកមាវើរណុនកំពុងតែនិយាយពីពិធីជប់លៀងអាហារពេលល្ងាចដ៏ភ្លឺភ្លើមួយនោះ។ គាត់គ្មាននិយាយអ្វីក្រៅពីរឿងហ្នឹងអស់ពីរសប្តាហ៍មកហើយ។ អ្នកសាងសង់ដែលមានគួរសមម្នាក់ និងប្រពន្ធរបស់គាត់នឹងមកបរិភោគអាហារពេលល្ងាច ហើយលោកមាវើរណុនកំពុងតែសង្ឃឹមថានឹងទទួលបាននូវការបញ្ជាទិញដ៏ធំមួយពីគាត់ (ក្រុមហ៊ុនរបស់លោកមាវើរណុនផលិតម៉ាស៊ីនខួង)។

- ខ្ញុំគិតថាយើងគួរតែហាត់សមពាក្យសម្តីម្តងទៀត- លោកមាវើរណុនបាននិយាយ។ - យើងទាំងអស់គ្នាគួរតែទៅកាន់តំនែងរៀងៗខ្លួននៅម៉ោងប្រាំបី។ ពីទូនៀ អូននឹងនៅ...?

- ក្នុងបន្ទប់ទទួលភ្ញៀវ- អ្នកមីងពីទូនៀបានស្រដីយ៉ាងរហ័ស - រង់ចាំស្វាគមន៍ពួកគេយ៉ាងគួរសមមកកាន់ផ្ទះរបស់យើង។

- ល្អ ល្អ។ ហើយដាត់លីវិញ?

- ខ្ញុំនឹងរង់ចាំបើកទ្វារ។- ដាត់លីបានបង្ហាញនូវស្នាមញញឹមចោលម្សៀតដែលមិនសប្បាយចិត្ត។ - តើខ្ញុំអាចយកអាវធំក្រៅរបស់អ្នកបានទេ លោក និងអ្នកស្រីមេសាន់?

- ពួកគេនឹងស្រលាញ់វាជាមិនខានឡើយ!- អ្នកមីងពីទូនៀស្រែកយ៉ាងសប្បាយចិត្ត។

- ល្អណាស់ ដាត់លី- លោកមាវើរណុនពោល។ បន្ទាប់មកគាត់បែរមករកហេរី។ - ហើយចុះឯងវិញ?

- ខ្ញុំនឹងនៅក្នុងបន្ទប់ដេករបស់ខ្ញុំ មិនបន្លឺសម្លេង ហើយធ្វើពុតជាខ្ញុំមិននៅទីនោះ- ហេរីនិយាយខ្សាវៗ។

- ប្រាកដជាអញ្ចឹងហើយ- លោកមាវើរណុនបាននិយាយយ៉ាងកាច។ - ខ្ញុំនឹងនាំផ្លូវពួកគេចូលទៅក្នុងបន្ទប់ទទួលភ្ញៀវណែនាំអូន ពីទូនៀ ហើយចាក់ភេសជ្ជៈឲ្យគេផឹក។ នៅម៉ោងប្រាំបីដប់ប្រាំនាទី...

- អូននឹងប្រកាសអាហារពេលល្ងាច- អ្នកមីងពីទូនៀបាននិយាយ។

- ហើយដាត់លី កូននិយាយថា...

- តើខ្ញុំអាចនាំអ្នកស្រីទៅបន្ទប់ទទួលទានអាហារបានដែរឺទេ អ្នកស្រីមេសាន់?- ដាត់លីបានស្រដី ដោយហុចដៃកន្ទាត់របស់វាទៅកាន់ស្ត្រីម្នាក់ដែលមើលមិនឃើញ។

- សុភាពបុរសតូចដ៏អស្ចារ្យរបស់ខ្ញុំ!- អ្នកមីងពីទូនៀឧទានឡើងស្ទើរមិនដកដង្ហើម។

- ហើយចុះឯងវិញ?- លោកមាវើរណុនបាននិយាយទៅកាន់ហេរីយ៉ាងកាចសាហាវ។

- ខ្ញុំនឹងនៅក្នុងបន្ទប់ដេករបស់ខ្ញុំ មិនបន្លឺសម្លេង ហើយធ្វើពុតជាខ្ញុំមិននៅទីនោះ- ហេរីនិយាយយ៉ាងធុញទ្រាន់។

- ច្បាស់ជាអញ្ចឹងហើយ។ ឥលូវ យើងគួរតែសំដៅរកការសរសើរល្អពីរបីនៅពេលអាហារពេលល្ងាចហើយ។ ពីទូនៀ មានគំនិតអីទេ?

- វើរណុនប្រាប់ខ្ញុំថាលោកគឺជាអ្នកវាយកូនគោលដ៏អស្ចារ្យម្នាក់ លោកមេសាន់...ប្រាប់ខ្ញុំមកមើល ថាតើអ្នកទិញរ៉ូបរបស់អ្នកនៅឯណា អ្នកស្រីមេសាន់...

- ល្អណាស់...ដាត់លី?

- យ៉ាងម៉េចដែរប្រសិនជាខ្ញុំនិយាយថា៖ "យើងត្រូវសរសេរសំនេរអំពីវីរៈបុរសរបស់យើងនៅឯសាលា លោកមេសាន់ ហើយខ្ញុំបានសរសេរអំពីលោក។"

រឿងនេះមានអត្ថន័យច្រើនពេកហើយសម្រាប់ទាំងហេរី និងអ្នកមីងពីទូនៀ។ អ្នកមីងពីទូនៀបានស្រែកយំ ហើយចាប់អោបកូនប្រុសរបស់គាត់ ខណៈពេលដែលហេរីអោនចុះក្រោមតុ អញ្ចឹងពួកគេនឹងមិនឃើញវាសើចនោះទេ។

- ហើយចុះឯងវិញ អាប្រមក់?

ហេរីបានបង្ខំចិត្តធ្វើឲ្យទឹកមុខរបស់វានៅធម្មតាខណៈពេលដែលវាងើបឡើង។

- ខ្ញុំនឹងនៅក្នុងបន្ទប់របស់ខ្ញុំ ដោយមិនបន្លឺសម្លេង ហើយធ្វើពុតជាខ្ញុំមិននៅទីនោះ- វាបាននិយាយ។

- ឯងនឹងធ្វើអញ្ចឹងប្រាកដណាស់- លោកមាវើរណុនបាននិយាយទាំងបង្ខំចិត្ត។ - គ្រួសារមេសាន់មិនដឹងរឿងអ្វីពីឯងនោះទេ ហើយវានឹងនៅតែអញ្ចឹងតទៅទៀត។ នៅពេលដែលអាហារពេលល្ងាចត្រូវបានបញ្ចប់ អូននាំអ្នកស្រីមេសាន់ទៅបន្ទប់ទទួលភ្ញៀវវិញដើម្បីពិសាកាផេ ពីទូនៀ ហើយបងនឹងយកប្រធានបទទាក់ទងនឹងម៉ាស៊ីនខួងមកនិយាយ។ ប្រសិនបើមានសំណាង បងនឹងទទួលបានការចុះហត្ថលេខាលើកិច្ចសន្យា ហើយបានសម្រេចមុនពត៌មានចេញផ្សាយនៅម៉ោងដប់។ យើងនឹងទៅដើរទិញអីវ៉ាន់សម្រាប់ផ្ទះថ្ងៃឈប់សម្រាកនៅក្នុងកោះម៉ាចរកានៅថ្ងៃស្អែកពេលនេះ។

ហេរីគ្មានអារម្មណ៍រំភើបអ្វីអំពីរឿងនេះទេ។ វាមិនគិតថាគ្រួសារឌើស្លីនឹងចូលចិត្តវានៅកោះម៉ាចរកាជាជាងនៅមហាវិថីប្រាយវេដ ដ្រាយនោះទេ។

- ល្អ...បងនឹងចុះទៅក្រុងរកមើលទិញអាវធំទទួលទានអាហារពេលល្ងាចសម្រាប់ដាត់លី ហើយនិងបង។ ហើយឯង- គាត់គ្រហឹមដាក់ហេរី - ឯងចេញឲ្យឆ្ងាយពីផ្លូវអ្នកមីងឯងពេលដែលគាត់កំពុងតែសម្អាតភ្លាមទៅ។

ហេរីចេញតាមទ្វារក្រោយ។ នេះជាថ្ងៃមង្គល និងជាថ្ងៃល្អមួយ។ វាដើរកាត់វាលស្មៅ ទម្លាក់ខ្លួនចុះលើបង់សួនច្បារ ហើយច្រៀងតិចៗថា៖

- រីករាយថ្ងៃកំណើត...រីករាយថ្ងៃកំណើត...

គ្មានកាត គ្មានអំនោយ ហើយវានឹងចំនាយពេលមួយល្ងាចដោយធ្វើពុតថាគ្មានរូបវា។ វាសម្លឹងមើលយ៉ាងវេទនាទៅក្នុងដើមឈើដែលដុះជាជួរ។ វាមិនដែលមានអារម្មណ៍ថាឯកោអ្វីម្ល៉េះទេ។ ច្រើនជាងអ្វីៗនៅសាលាហុកវ៉ាត ថែមទាំងច្រើនជាងការលេងកីឡាឃ្វីដឌីច្ឆទៅទៀត ហេរីនឹកមិត្តដ៏ជិតស្និទ្ធិបំផុតរបស់វា រ៉ុន វីស្លី និងហឺម៉ាយអូនី ហ្គ្រេនជឺរ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេហាក់ដូចជាមិននឹកវាទាល់តែសោះ។ គ្មាននរណាម្នាក់ក្នុងចំនោមពួកគេ សរសេរសំបុត្រមកវាទាល់តែសោះពេញមួយរដូវក្តៅហើយ ទោះបីជារ៉ុនបាននិយាយថាវានឹងស្នើសុំហេរីមកស្នាក់នៅជាមួយក៏ដោយ។

អស់វេលាជាច្រើនរាប់មិនអស់ដែល ហេរី ធ្លាប់គិតប្រុងនឹងចាក់សោបើកទ្រុងរបស់ ហ៊ីដវីក ដោយវេទមន្ត រួចបញ្ជូនវាទៅ រ៉ុន និង ហឺម៉ាយអូនី ជាមួយនឹងសំបុត្រមួយច្បាប់ ប៉ុន្តែវាមិនដល់ថ្នាក់ប្រថុយនឹងគ្រោះថ្នាក់នេះទេ។ វេទគូមិនគ្រប់អាយុមិនអនុញ្ញាតឲ្យប្រើប្រាស់វេទមន្តនៅក្រៅសាលានោះទេ។ ហេរីមិនបានប្រាប់គ្រួសារឌើស្លីពីរឿងនេះទេ វាដឹងថាវាគ្រាន់តែជាភាពភ័យខ្លាចរបស់ពួកគេប៉ុណ្ណោះ ដែលថាវាប្រហែលជាជប់ពួកគេឲ្យក្លាយជាអាច់សត្វល្អិត ដើម្បីបញ្ឈប់ពួកគេមិនឲ្យចាក់សោឃុំវាទុកនៅក្នុងបន្ទប់ក្រោមជណ្តើរជាមួយនឹងចង្កឹះវេទមន្ត និងអំបោសហោះរបស់វា។ នៅពីរសប្តាហ៍ដំបូងពេលត្រលប់មកវិញ ហេរីពេញចិត្តនឹងការនិយាយរអ៊ូរទាំនូវពាក្យសម្តីមិនបានការតិចៗ ហើយនឹងការមើលដាត់លីចេញពីបន្ទប់យ៉ាងលឿនតាមដែលជើងកន្ទាត់របស់វាឃ្លូរវារួច។

ប៉ុន្តែការបាត់ដំណឹងដ៏យូរពី រ៉ុន និង ហឺម៉ាយអូនី បានធ្វើឲ្យ ហេរី មានអារម្មណ៍ថាត្រូវបានដាច់ចេញពីពិភពវេទមន្ត ដែលថាសូម្បីតែការចំអកឡកឡឺយដាក់ ដាត់លី ក៏បានបាត់បង់ចំនង់អស់ដែរ ... ហើយឥលូវរ៉ុន និងហឺម៉ាយអូនីបានភ្លេចថ្ងៃខួបកំណើតរបស់វាហើយ។

ឥលូវ តើមានអ្វីទៅ ដែលវាមិនហ៊ានលះបង់ដើម្បីដោះដូរនឹងសារមួយច្បាប់ពីសាលាហុកវ៉ាតនោះ? ពីមេធ្មប់ រឺក៏វេទគួណាម្នាក់នោះ? វាប្រាកដជាស្ទើរតែត្រេកអរណាស់ទៅហើយ ប្រសិនបើបានឃើញសត្រូវទីមួយរបស់វា គឺ ដ្រាកូ មេលហ្វ័យ ដោយគ្រាន់តែចង់បញ្ជាក់ថារឿងរ៉ាវទាំងអស់ហ្នឹងមិនមែនជាសុបិនឡើយ...

មិនមែនថាពេញមួយឆ្នាំរបស់វានៅឯសាលាហុកវ៉ាតសុទ្ធតែសប្បាយទាំងអស់នោះទេ។ នៅពេលហៀបនឹងជិតចប់ឆមាសចុងក្រោយ ហេរីបានប្រឈមមុខជាមួយនឹង គ្មាននរណាក្រៅពី វ៉ុលដឺម៉រ ដោយខ្លួនវាផ្ទាល់នោះទេ។ វ៉ុលដឺម៉រ ប្រហែលជាបានបំផ្លាញរាងកាយពីអតីតរបស់គាត់ដោយផ្ទាល់ដែឯងមែន ប៉ុន្តែគាត់នៅតែធ្វើឲ្យគេភ័យខ្លាច នៅតែមានល្បិចកល នៅតែប្ដេជ្ញាចិត្តក្នុងការទទួលបាននូវថាមពលឡើងវិញ។ ហេរីបានរបូតចេញពីអន្ទាក់របស់វ៉ុលដឺម៉រជាលើកទីពីរហើយ ប៉ុន្តែវាជាការគេចខ្លួនដ៏តូចចង្អៀតមួយ ហើយសូម្បីតែឥលូវ ហេរីនៅតែភ្ញាក់ឡើងនៅពេលយប់ ដោយទទឹកជោកក្នុងអាវរងាដ៏ត្រជាក់ ឆ្ងល់ថាតើឥលូវ វ៉ុលដឺម៉រ នៅឯណា ដោយចងចាំនូវទឹកមុខដ៏ខឹងសម្បាររបស់គាត់ ភ្នែកដ៏ព្រៃផ្សៃធំៗរបស់គាត់...

ភ្លាមនោះហេរីអង្គុយត្រង់ខ្លួនភ្លឹងនៅលើបង់សួនច្បារ។ វាកំពុងតែសម្លឹងមើលទៅដើមឈើដែលដុះជាជួរដោយភាំងៗ... ហើយដើមឈើដែលដុះជាជួរនោះសម្លឹងមើលមកវិញ។ ភ្នែកពណ៌បៃតងធំៗពីរបានលេចឡើងក្នុងចំនោមស្លឹកឈើទាំងនោះ។

ហេរីបានក្រោកឈរឡើងខណៈពេលដែលសម្លេងសើចចំអកអណ្ដែតកាត់វាលស្មៅ។

- ខ្ញុំដឹងថាថ្ងៃនេះជាថ្ងៃអ្វីហើយ- ដាត់លីបានច្រៀង ដោយដើរទ្រេតទ្រោតៗសំដៅមករកវា។

ភ្នែកដ៏ធំទាំងពីរនោះបានព្រិច ហើយក៏រលាយបាត់។

- អីគេ?- ហេរីបាននិយាយ ដោយមិនគ្រវាសភ្នែកចេញពីកន្លែងដែលវាសម្លឹង។

- ខ្ញុំដឹងថាថ្ងៃនេះជាថ្ងៃអ្វីហើយ- ដាត់លីបាននិយាយម្ដងទៀត ដោយដើរឡើងសំដៅមករកវា។

- ល្អណាស់- ហេរីបាននិយាយ។ - អញ្ចឹងចុងបញ្ចប់ឯងបានរៀនថ្ងៃក្នុងមួយសប្ដាហ៍ចាំអស់ហើយ។

- ថ្ងៃនេះជាថ្ងៃខួបកំណើតរបស់ឯង- ដាត់លីបាននិយាយមើលងាយ។ - ម៉េចក៏ឯងមិនទទួលបានកាតអីសោះអញ្ចឹង? តើឯងគ្មានមិត្តនៅកន្លែងចម្លែកនោះទេរឺ?

- យល់ល្អកុំឲ្យម៉ាក់របស់ឯងដឹងថាឯងនិយាយពីសាលារបស់ខ្ញុំអី- ហេរីបាននិយាយយ៉ាងសោះកក្រោះ។

ដាត់លីបានលើកខោរបស់វាឡើង ដែលកំពុងតែរអិលចុះក្រោមគូទកន្ទាត់របស់វា។

- ហេតុអ្វីបានជាឯងសម្លឹងមើលដើមឈើដែលដុះជាជួរនោះ?- វាបាននិយាយទាំងសង្ស័យ។

- ខ្ញុំកំពុងតែព្យាយាមសម្រេចចិត្តថាតើអ្វីគឺជាពាក្យវេទមន្តដ៏ល្អបំផុតសម្រាប់បញ្ឆេះវា- ហេរីបាននិយាយ។

ដាត់លីដើរថយក្រោយភ្លាមមួយរំពេច ដោយមានសភាពស្លន់ស្លោរនៅលើមុខកន្ទាត់របស់វា។

- ឯងមិន ... មិនអាច ... ប៉ាបានប្រាប់ឯងថាមិនឲ្យប្រើប្រាស់វេទមន្តនោះទេ...គាត់និយាយថាគាត់នឹងគ្រវែងឯងចេញពីផ្ទះ...ហើយឯងគ្មានកន្លែងដែលត្រូវទៅទៀតទេ...ឯងគ្មានមិត្តភក្តិមកយកឯងនោះទេ...

- ជីកគ័រី ផក់យើរី!- ហេរីបាននិយាយយ៉ាងសាហាវ។ - ហូខស់ ផូខស់...ស្ទីកគ្លី វីកគ្លី...

- ម៉ាកកកកក់!- ដាត់លីបានស្រែក ដោយជំពប់ជើងរបស់វា ខណៈពេលដែលវាបែរត្រលប់ក្រោយទៅផ្ទះវិញ។ -ម៉ាកកក់! វាកំពុងតែធ្វើអ្វីដែលម៉ាក់ដឹងស្រាប់ហើយ!

ហេរីបានសងយ៉ាងជាទីគាប់ចិត្តចំពោះពេលសប្បាយរបស់វានេះ។ ដោយដាត់លី រីក៏ដើមឈើដែលដុះជាជួរគ្មានខូចខាតអ្វី អ្នកមីងពីទូនៀដឹងថាវាមិនមែនប្រាកដជាប្រើវេទមន្តនោះទេ ប៉ុន្តែវាត្រូវតែឱនចុះខណៈពេលដែលគាត់តម្រង់គប់ឆ្នាំងខ្ទះដែលមានសាប៊ូមករកក្បាលវា។ បន្ទាប់មកគាត់ឲ្យការងារវាធ្វើ ជាមួយនឹងពាក្យសន្យាថាវានឹងមិនហូបអ្វីឡើយលុះត្រាតែវាធ្វើការងារចប់សព្វគ្រប់។

ខណៈពេលដែលដាត់លីកំពុងតែដើរត្រេតត្រតនៅជុំវិញ និងហូបការ៉េម ហេរីនៅសម្អាតបង្អួច លាងឡាន ច្រូតស្មៅ លំអសួនផ្កា កាត់និងស្រោចផ្កាកុលាប ហើយលាបពណ៌ថ្នាំបង់សួនច្បារឡើងវិញ។ ព្រះអាទិត្យកំពុងតែឆាបឆេះនៅពីលើក្បាល ដោយធ្វើឲ្យកខាងក្រោយរបស់វាខ្លោច។ ហេរីបានដឹងថាវាមិនគួរលើកនុយរបស់ដាត់លីនោះទេ ប៉ុន្តែដាត់លីបាននិយាយនូវអ្វីដែលហេរីកំពុងតែគិត...ប្រហែលជាវាគ្មានមិត្តនៅសាលាហុកវ៉ាតនោះទេ...

- សូមប្រាថ្នាថាពួកគេអាចជួបហេរី ផោតធ័រដ៏ល្បីឈ្មោះនាពេលឥលូវនេះចុះ- វាបានគិតយ៉ាងខឹងសម្បារ ខណៈពេលដែលវាបាចដីទៅលើសួនផ្កា ខ្នងរបស់វាកំពុងតែឈឺចាប់ ញើសហូរចុះមុខរបស់វា។

- ចូលមកក្នុងនេះមក! ហើយដើរលើក្រដាសកាសែតទៅ!

ហេរីធ្វើដំណើរយ៉ាងត្រេកអរទៅក្នុងម្លប់នៃផ្ទះបាយដែលភ្លឺចិញ្ចែងចិញ្ចាច។ នៅខាងលើទូទឹកកកមានបញ្ជូរពូឌិញសំរាប់យប់នេះ៖ គំនរការ៉េមដ៏ធំមួយ និងតំណាប់ស្វាយដាក់ស្ករ។ សាច់ជ្រូកខ្វៃមួយដុំកំពុងតែចំអិននៅក្នុងឡ។

- ស៊ីឲ្យលឿនឡើងទៅ! គ្រួសារមេសាន់នឹងមកទីនេះក្នុងពេលឆាប់ៗនេះហើយ!- អ្នកមីងពីទូនៀនិយាយម៉ាត់ៗ ដោយចង្អុលទៅនំប៉័ងពីរដុំ ហើយនិងប្រូម៉ាស់មួយដុំនៅលើតុផ្ទះបាយ។ គាត់បានស្លៀកពាក់នូវរ៉ូបកន្ទុយមាន់ត្រីសូម៉ុងពណ៌ផ្កាឈូករួចទៅហើយ។

ហេរីលាងដៃរបស់វា ហើយលេបអាហារពេលយប់របស់វាយ៉ាងគួរឲ្យអាណិត។ នៅពេលដែលវាហូបរួច អ្នកមីងពីទូនៀបានយកចានរបស់វាចេញ។ - ឡើងទៅលើទៅ! លឿនឡើង!

ខណៈពេលដែលវាដើរកាត់ទ្វារទៅកាន់បន្ទប់ទទួលភ្ញៀវ ហេរីបានក្រលេកឃើញលោកមាវើរណុន និងដាត់លីពាក់ក្រវ៉ាត់ករាងកោង និងអាវធំសម្រាប់អាហារពេលល្ងាច។ វាទើបតែទៅដល់កាំជណ្ដើរចុងក្រោយស្រាប់តែកណ្ដឹងទ្វារផ្ទះបានរោទិ៍ឡើង ហើយមុខដ៏ខឹងសម្បាររបស់លោកមាវើរណុនបានលេចឡើងនៅឯងជើងជណ្ដើរ។

- ចាំណាំ អាច្រមក់ ... ហ៊ានតែបន្លឺសម្លេងអ្វីមួយនោះ...

ហេរីបានដើរកាត់ទៅបន្ទប់របស់វាដោយលបៗ ចូលទៅក្នុង បិទទ្វារ ហើយបែរទៅផ្ដួលខ្លួននៅលើគ្រែរបស់វា។

បញ្ហាគឺថា មាននរណាម្នាក់កំពុងតែអង្គុយនៅលើគ្រែបាត់ទៅហើយ។